# ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ២៤៤(២០១៣) មនុស្សឃាដគិតទុកជាមុន

**ពាក្យគន្លឹះ៖** មនុស្សឃាដគិតទុកជាមុន, សំអាងហេតុ, ឯកត្តកម្មនៃទោស, បន្ទុកនិងកម្រិតភស្តុតាង

## ១.អង្គហេតុនិងប្រវត្តិនីតិវិធី

ក្នុងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ ក្នុងខ័ណ្ឌដង្កោ រាជធានីភ្នំពេញ មានអំពើសម្លាប់មនុស្សមួយករណី។ អង្គហេតុនេះត្រូវបានចោទជាបទមនុស្សឃាដគិតទុកជាមុន លើបុគ្គលចំនួន៧នាក់ (ម្នាក់អាយុ១៥ឆ្នាំ) តាមមាត្រា៣នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ សាលាដំបូងរាជធានីភ្នំពេញ បានចេញសាលក្រមលេខ២៤៨ ខែឧសភា ឆ្នាំ២០១១ សម្រេចដាក់គុក ៧ឆ្នាំដល់អនីតិជន និង១៥ឆ្នាំ លើបុគ្គលចំនួន៦រូបផ្សេងទៀត។ ជនជាប់ចោទទាំងអស់បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រម។ តំណាងអយ្យការអមសាលាឧទ្ធរណ៍ អះអាងថា ពុំមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទទាំង៧នាក់។ សាលាឧទ្ធរណ៍បានចេញសាលដីកាកំបាំងមុខលេខ៤៦ មេសា ឆ្នាម២០១២ តម្កល់សាលក្រមលេខ២៤៨។ សាលាឧទ្ធរណ៍បានចេញសាលដីកាលេខ១០៤ វិច្ឆិកាឆ្នាំ២០១២តម្កល់សាលដីកាកំបាំងមុខលេខ៤៦។ អ្នកទាំង៧រូបបានប្តឹងសាទុក្ខ។ តំណាងមហាអយ្យការអមតុលាការកំពូលស្នើឲ្យបដិសេធសាលដីកាលេខ១០៤។ មេធាវីស្នើអះអាងថាមានវិមតិសង្ស័យ និងស្នើសុំបដិសេធសាលដីកា។ តុលាការកំពូលបានចេញសាលដីកាលេខ២៤៤ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៣។

## ២.សំអាងហេតុនិងសេចក្តីសម្រេច

តុលាការកំពូលបានពិចារណានិងយល់ឃើញថា *ការដែលសាលាដំបូងរាជធានីភ្នំពេញ និងសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍សំរេចផ្តន្ទាទោស......ពុំទាន់មានមូលដ្ឋានគ្រប់គ្រងដើម្បីកំណត់អង្គហេតុនៃបទល្មើសនិងធាតុផ្សំនៃបទល្មើស លើជនជាប់ចោទម្នាក់ៗអោយបានច្បាប់លាស់ទេ ។ ទាំងសាលាដំបូង ទាំងសាលាឧទ្ធរណ៍ ក្នុងការយល់ឃើញ ពុំឃើញមានបង្ហាញនូវអង្គហេតុស្ថាពរ ដែលកំណត់ថាជនត្រូវចោទម្នាក់ៗ មានសកម្មភាពយ៉ាងដូចម្តេចនៅក្នុងបទល្មើសនេះឡើយ ដូច្នេះសាលដីការបស់សាលាឧទ្ធរណ៍នេះ មានកំហុសរំលោភទៅលើមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។*

**សម្រេច៖** ២.បដិសេធសាលដីកាលេខ១០៤...៣.បញ្ជូនសំណុំរឿង...ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

## ៣.កំណត់សំគាល់

១. ក្នុងសំណុំរឿងនេះ មិនមានសាក្សីណាឃើញសកម្មភាពប្រព្រឹត្តផ្ទាល់ទេ។ របាយការណ៍ប៉ូលីស មិនបានបញ្ជាក់ថាជាករណីប្លន់ឬ គ្រោះថ្នាក់ចរាចរណ៍..ឃើញម៉ូតូដួល ហើយមនុស្សពីរនាក់ជិះម៉ូតូនោះ ក្រោយពីប៉ូលីសបាញ់ អ្នកនោះផ្តួលម៉ូតូរួចរត់។ ជនជាប់ចោទទាំងអស់ ត្រូវបានឃាត់ខ្លួន ពីឬបីថ្ងៃក្រោយថ្ងៃកើតហេតុ។

២. តុលាការកំពូល យោងយល់មាត្រា៤១៩ ជាមូលដ្ឋាននៃប្តឹងសាទុក្ខ ដែមូលដ្ឋានមួយក្នុងនោះ គឺសំអាងហេតុមិនគ្រប់គ្រាន់។ តុលាការនេះ យោងទៅដល់អង្គហេតុជាស្ថាពរ ដែលអាចនិយាយថា អង្គហេតុរឹងមាំ ចុងក្រោយ នាំឲ្យសន្និដ្ឋានថាបទល្មើសកើតមានឡើង និងបង្ហាញអំពីធាតុផ្សំនៃបទល្មើស (ធាតុសំភារៈ និងធាតុអត្តនោម័ត)។ បន្ថែមពីលើនេះ ខ្លឹមសារដកស្រង់ខាងលើ បានបង្ហាញពីការទាមទារឲ្យបង្ហាញការចូលរួមរបស់ជនជាប់ចោទម្នាក់ៗជាក់លាក់ នាំទៅរកការទទួលខុសត្រូវតាមទម្រង់ផ្សេងៗ ដូចជាការប្រព្រឹត្ត ឬសមគំនិត ដើម្បីឈានទៅដាក់ទោសម្នាក់ៗ អនុលោមតាមគោលការណ៍ឯកត្តកម្មនៃទោស និងការទទួលខុសត្រូវ (មាត្រា២៤នៃក្រុមព្រហ្មទណ្ឌ)។ ព្រះរាជអាជ្ញាគ្រប់កម្រិតអះអាងថា មិនមានភស្តុតាងដាក់បន្ទុក។

៣. នេះពាក់ព័ន្ធនឹងបន្ទុក និងកម្រិតនៃភស្តុតាង ដែលព្រះរាជអាជ្ញាត្រូវបង្ហាញ ដើម្បីមិនឲ្យមានការបំពានគោលការណ៍សន្មត់ថាមិនមានទោស (មាត្រា៣៨នៃច្បាប់រដ្ឋធម្មនុញ្ញ មាត្រា១៤.២នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ)។ អវតក បានទាមទារឲ្យព្រះរាជអាជ្ញា បង្ហាញភស្តុតាងកម្រិតហួសពីវិមតិសង្ស័យ លើធាតុផ្សំបទល្មើសនិងទម្រង់នៃការចូលរួម (សាលក្រមសាលាដំបូង អវតក E188 កថា៤៤)។

សម្រាប់សំណុំរឿងពាក់ព័ន្ធបន្ទុកភស្តុតាង សូមមើល (សាលដីកាលេខ២២៧ ឆ្នាំ១៩៩៨) និង ហួសពីវិមតិសង្ស័យ សូមមើលសេចក្តីដកស្រង់សាលដីកាលេខ២២៣៩ឆ្នាំ២០១៣ (ចំណុច៣.៥ និង៣.៦) (មាស បូរ៉ា ខ្លឹមសារដកស្រង់សាលដីកាតុលាការកំពូល ឆ្នាំ២០១២, ទំ. ១១២)។